# ៧- រឿងបុរស ៣ ឈ្លោះដណ្តើមដំណោកគ្នា

មាននិទានមួយថា : មានបុរស ៣ នាក់វិវាទជជែកប្រកែក ដណ្តើមដំណោកគ្នា ចង់ដេកកណ្តាលតែរៀងខ្លួន ។ បុរសទាំង ៣ នាក់នោះក្រវើនតែ១ ប្រកែកជជែកគ្នាទៅវិញទៅមក ក៏ខានបានដេកយប់នោះ ។ លុះព្រឹកឡើងក៏នាំគ្នាទៅរកចៅក្រម ប្តឹងដោយដំណើរទីទៃ ៗ ។ ចៅក្រមពិចារណាក្តីនេះពុំដាច់ស្រេច ក៏នាំបុរសទាំង ៣ នាក់ទៅក្រាបបង្គំទូលព្រះមហាក្សត្រ ដោយដំណើរនោះ ។ ព្រះអង្គទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ព្រះតម្រិះដោយព្រះប្រាជ្ញា ឈ្វេងយល់ក្នុងព្រះវិចារណញ្ញាណ ហើយទ្រង់ត្រាស់បង្គាប់ថា "ចូរព្រះស្តែងទាំង ៣ នាក់ដេកយកក្បាលឈមជុំចូលរកគ្នា នេះឯងហៅថាដេកកណ្តាលគ្រប់គ្នាហោង " ។

បុរសទាំង ៣ នាក់ទទួលព្រះបន្ទូលនោះហើយ ក៏ក្រាបថ្វាយបង្គំលាព្រះមហាក្សត្រទៅលំនៅរៀងខ្លួន ។

ព្រះមហាក្សត្រទ្រង់កាត់សេចក្តីដូច្នេះ ហៅសុគតិគមនំហោង ។